| ៧ | លោក អ៊ី លាហេង | គ្រូបង្រៀនកំរិតបឋម | បឋមសិក្សាកោះម្សៀល | ស្រុកកោះញែក |

**ខ-មេដាយប្រាក់ការងារ :**

| | | | | |
|---|---|---|---|---|
| ១ | លោក ចាន់ វណ្ណា | ប្រធានការិយាល័យ ក្រៅប្រពន្ធ័ | មន្ទីរអប់រំ | ក្រុងសែនមនោរម្យ |
| ២ | លោក សោម ឧត្តរី | ប្រធានការិយាល័យ អធិការកិច្ច | មន្ទីរអប់រំ | ក្រុងសែនមនោរម្យ |
| ៣ | លោក ខៀន ញឹម | អនុប្រធានការិយាល័យ ក្រៅប្រពន្ធ័ | មន្ទីរអប់រំ | ក្រុងសែនមនោរម្យ |
| ៤ | លោក គឹម ថាន | មន្ត្រីការិយាល័យរដ្ឋបាល បុគ្គលិក | អនុ.អូររះស្ពិត | ក្រុងសែនមនោរម្យ |
| ៥ | លោក ចាក់ ធប់ | អនុប្រធានការិយាល័យអប់រំស្រុក | ការិ. អប់រំស្រុកអូររាំង | ស្រុកអូររាំង |

| | | | | |
|---|---|---|---|---|
| ៦ | លោក កែវ វិបុល | គ្រូបង្រៀន | វិ.ហ៊ុន សែន មណ្ឌលគិរី | ក្រុងសែនមនោរម្យ |
| ៧ | លោកស្រី ទូច សីលា | គ្រូបង្រៀន | វិ.ហ៊ុន សែន មណ្ឌលគិរី | ក្រុងសែនមនោរម្យ |
| ៨ | លោក លុក ភាក់ | គ្រូបង្រៀន | បឋ.ហ៊ុន សែន កោះញែក | ស្រុកកោះញែក |
| ៩ | លោក សួម រ៉ាន់នែត | គ្រូបង្រៀន | បឋមសិក្សាកែវសីមា ហ៊ុន សែន | ស្រុកកែវសីមា |
| ១០ | លោក ម៉ម សារ៉ុត | គ្រូបង្រៀន | បឋមសិក្សាស្រែអំពូយ | ស្រុកកែវសីមា |

**គ.មេដាយសំរឹទ្ធការងារ :**

| | | | | |
|---|---|---|---|---|
| ១ | លោក ទុច ស៊ីណា | ប្រធានការិយាល័យយុវជន និងកីឡា | មន្ទីរអប់រំ | ក្រុងសែនមនោរម្យ |
| ២ | លោក ជា សុជាតិ | អនុប្រធានការិយាល័យបឋម | មន្ទីរអប់រំ | ក្រុងសែនមនោរម្យ |
| ៣ | លោក កែវ វដ្ឋា | អនុប្រធានការិយាល័យ យុវជន និងកីឡា | មន្ទីរអប់រំ | ក្រុងសែនមនោរម្យ |
| ៤ | លោក ស្រួម គាញ់ | ប្រធានការិយាល័យ អប់រំស្រុក | ការិយាល័យ អប់រំស្រុក | ស្រុកកោះញែក |
| ៥ | លោក ញ៉ើប គីមស៊ាន | ប្រធានការិយាល័យ អប់រំស្រុក | ការិយាល័យ អប់រំស្រុក | ស្រុកកែវសីមា |
| ៦ | លោកស្រី ជុំ បូភី | មន្ត្រីការិ.វដ្ឋបាល បុគ្គលិក និងបណ្តុះបណ្តាល | មន្ទីរអប់រំ | ក្រុងសែនមនោរម្យ |
| ៧ | លោក អ៊ិន ម៉ាំង | មន្ត្រីការិ.ផែនការគណនេយ្យ និងសំភារៈ | មន្ទីរអប់រំ | ក្រុងសែនមនោរម្យ |
| ៨ | លោក អ៊ិត សារឿន | មន្ត្រីការិយាល័យ អប់រំស្រុក | ការិយាល័យ អប់រំស្រុក | ស្រុកកោះញែក |
| ៩ | លោក ណយ សារ៉ាន់ | មន្ត្រីការិយាល័យ អប់រំស្រុក | ការិយាល័យ អប់រំស្រុក | ស្រុកកែវសីមា |
| ១០ | លោកស្រី សុខ សារ៉ុំ | គ្រូបង្រៀន | វិ.ហ៊ុន សែន មណ្ឌលគិរី | ក្រុងសែនមនោរម្យ |
| ១១ | លោកស្រី ថាល់ សត្ថា | គ្រូបង្រៀន | វិ.ហ៊ុន សែន មណ្ឌលគិរី | ក្រុងសែនមនោរម្យ |
| ១២ | លោក ទូច សុគន្ធ | គ្រូបង្រៀន | អនុវិ.ហ៊ុន សែន កោះញែក | ស្រុកកោះញែក |
| ១៣ | លោកស្រី ហែម រម្យនា | គ្រូបង្រៀន | អនុវិ.ហ៊ុន សែន អូររាំង | ស្រុកអូររាំង |
| ១៤ | លោក ញ៉ីវ រិទ្ធ | គ្រូបង្រៀន | បឋមសិក្សាពូ ក្រេង | ស្រុកពេជ្រាដា |
| ១៥ | លោកស្រី ទើក ចិន្តា | គ្រូបង្រៀន | សាលាមត្តេយ្យសង្គមរាស្ត្រនិយម | ក្រុងសែនមនោរម្យ |
| ១៦ | លោកស្រី វិន ឡារី | គ្រូបង្រៀន | បឋមសិក្សាឡៅការ | ក្រុងសែនមនោរម្យ |
| ១៧ | លោក សាង រ៉ា | គ្រូបង្រៀន | បឋ.ហ៊ុន សែន សែនមនោរម្យ | ក្រុងសែនមនោរម្យ |
| ១៨ | លោកស្រី ថែម សិភ័ក្រ | គ្រូបង្រៀន | បឋមសិក្សា ពុហ្សាម | ស្រុកអូររាំង |
| ១៩ | លោកស្រី ឈាង ចិន្តា | គ្រូបង្រៀន | បឋមសិក្សា ពូទ្រេក្រោម | ស្រុកអូររាំង |

**មាត្រា២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និងអភិបាលនៃគណៈអភិបាលខេត្តមណ្ឌលគិរី ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។/.

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ឆ្នាំ២០១០

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ២៥៥ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការតែងតាំងក្រុមប្រឹក្សាភិបាល

## សហគ្រាសសាធារណៈភ្នាក់ងារកម្ពុជានាវាចរ "កាំសាប"

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ ជស/រកម/០៦៩៦/០៣ ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/០៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសាធារណការ និងដឹកជញ្ជូន
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/១១០៨/១១៩៣ ចុះថ្ងៃទី ០៣ ខែ វិច្ឆិកា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជាប្រធានអគ្គនាយក
- បានឃើញអនុក្រឹត្យ លេខ ១៤ អនក្រ.បក ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន
- បានឃើញអនុក្រឹត្យ លេខ ៨១ អនក្រ.បក ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ១៩៩៩ ស្តីពីការបង្កើតសហគ្រាសសាធារណៈភ្នាក់ងារកម្ពុជានាវាចរ "កាំសាប"
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន

## សម្រេច

**មាត្រា ១ៈ** ត្រូវបានតែងតាំងក្រុមប្រឹក្សាភិបាល នៃសហគ្រាសសាធារណៈភ្នាក់ងារកម្ពុជានាវាចរ "កាំសាប" សំរាប់អាណត្តិទី ៤ ដែលមានសមាសភាពដូចខាងក្រោម :

១- ឯកឧត្តម **រស់ វិណ្ណា** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាប្រធានអគ្គនាយក "កាំសាប" ជាប្រធាន

| | | | |
|---|---|---|---|
| ២- លោកជំទាវ | **មីន មាណវី** | តំណាងក្រសួងសាធារណការ និងដឹកជញ្ជូន | ជាសមាជិក |
| ៣- ឯកឧត្តម | **ឃុយ ហៀង** | តំណាងទីស្តីការគណៈរដ្ឋមន្ត្រី | ជាសមាជិក |
| ៤- លោក | **នេត មុន្នី** | តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ជាសមាជិក |
| ៥- ឯកឧត្តម | **លី ផាណ្ណា** | តំណាងក្រសួងពាណិជ្ជកម្ម | ជាសមាជិក |
| ៦- ឯកឧត្តម | **ស៊ាង ប៊ុនលាង** | តំណាងក្រសួងមហាផ្ទៃ | ជាសមាជិក |
| ៧- លោក | **ញ្ញាន សុកុល** | តំណាងនិយោជិតភ្នាក់ងារកម្ពុជានាវាចរ " កាំសាប " | ជាសមាជិក ។ |

**មាត្រា ២៖** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន ដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា១ ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី១៨ ខែ ០៣ ឆ្នាំ២០១០

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

<u>កន្លែងទទួល</u> ៖
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ.២៧.៥១...អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការតែងតាំង

## ក្រុមប្រឹក្សាភិបាលកំពង់ផែស្វយ័តភ្នំពេញ "ក.ស.ភ"

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- ព្រះរាជក្រឹត្យ លេខ នស/រកត/០៨០៨/៩៤៤ ចុះថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងប្រតិភូរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើប្រាស់ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ លេខ ជស/រកម/០៦៩៦/០៣ ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើប្រាស់ច្បាប់ ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/០៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើប្រាស់ច្បាប់ ស្តីពីការបង្កើតក្រសួងសាធារណការ និងដឹកជញ្ជូន
- បានឃើញអនុក្រឹត្យ លេខ ១៤ អនក្រ.បក ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន
- បានឃើញអនុក្រឹត្យលេខ ៥១ អនក្រ.បក ចុះថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ១៩៩៨ ស្តីពីការបង្កើតកំពង់ផែស្វយ័តភ្នំពេញ "ក.ស.ភ"
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន

## សម្រេច

**មាត្រា ១:** ត្រូវបានតែងតាំងក្រុមប្រឹក្សាភិបាលកំពង់ផែស្វយ័តភ្នំពេញ សំរាប់អាណត្តិទី ៤ ដែលមានសមាសភាព ដូចខាងក្រោម :

| | | | |
|---|---|---|---|
| ១- ឯកឧត្តម | ហ៊ី បារី | ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជាប្រធានអគ្គនាយក កំពង់ផែស្វយ័តភ្នំពេញ | ជាប្រធាន |
| ២- ឯកឧត្តម | ស្នួត សំបូរ | តំណាងក្រសួងសាធារណការ និងដឹកជញ្ជូន | ជាសមាជិក |
| ៣-ឯកឧត្តម | លី ស៊ីវណ្ណា | តំណាងទីស្តីការគណៈរដ្ឋមន្ត្រី | ជាសមាជិក |
| ៤- លោក | កែន សម្បត្តិ | តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ជាសមាជិក |
| ៥- លោក | ចម បូរិទ្ធ | តំណាងក្រសួងពាណិជ្ជកម្ម | ជាសមាជិក |
| ៦- លោក | ទីវ គីមពិសិដ្ឋ | តំណាងសាលារាជធានីភ្នំពេញ | ជាសមាជិក |
| ៧- លោកស្រី | គីម សែន | តំណាងនិយោជិតកំពង់ផែស្វយ័តភ្នំពេញ | ជាសមាជិក ។ |

**មាត្រា ២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័ន ដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ ០៣ ឆ្នាំ ២០១០

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ២៨៥ អនក្រ.តត

## អនុក្រឹត្យ

## ស្តីពីការជូនគ្រឿងឥស្សរិយយសមុនីសារាភ័ណ្ឌ

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើប្រាស់ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

### សម្រេច

**មាត្រា១.—**

ត្រូវបានបំពាក់ **គ្រឿងឥស្សរិយយសមុនីសារាភ័ណ្ឌ** តាមលំដាប់ថ្នាក់ ផ្តល់ជូនមន្ត្រីរាជការ និងសប្បុរសជនចំនួន ០២រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួនជួយកសាងសមិទ្ធផលនានាក្នុងវិស័យ ព្រះពុទ្ធសាសនា និងហេដ្ឋារចនាសម្ព័ន្ធតមនាគមន៍ ស្ថិតនៅក្នុងឃុំធិបតី ស្រុកគាស់ក្រឡ ខេត្តបាត់ដំបង ដែលមានរាយនាមដូចខាងក្រោម :

**ក. មេដាយមុនីសារាភ័ណ្ឌថ្នាក់ធិបឌិន្ទចំនួន ០១ គ្រឿង ផ្តល់ជូន**

លោក **ប៉ែន វុទ្ធី** សប្បុរសជននៅរាជធានីភ្នំពេញ

**ខ. មេដាយមុនីសារាភ័ណ្ឌថ្នាក់សេនាចំនួន ០១ គ្រឿង ផ្តល់ជូន**

លោកអនុសេនីយ៍ទោ **មួច សារ៉េន** មេបញ្ជាការអន្តរាគមន៍កងរាជអាវុធហត្ថខេត្ត

**មាត្រា២.—**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អភិបាលខេត្តបាត់ដំបង និង សាមីខ្លួន ដែលមានឈ្មោះក្នុងមាត្រា១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ ៣ ឆ្នាំ២០១០

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ២៥៨ អនក្រ.បក

## អនុក្រឹត្យ

## ស្ដីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្ដីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១.–**

ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ប្រគេន និងផ្ដល់ជូនសប្បុរសជននៅក្នុង និងក្រៅប្រទេស ចំនួន ៣០រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួនជួយកសាងសមិទ្ធផលនានាក្នុងវិស័យ ព្រះពុទ្ធសាសនា និងហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ ស្ថិតនៅក្នុងឃុំធិបតី ស្រុកគាស់ក្រឡ ខេត្តបាត់ដំបង ដែលមានរាយព្រះនាម និងនាមដូចខាងក្រោម :

**ក. មេដាយមាសស្ថាបនាជាតិចំនួន ១៧ គ្រឿង ប្រគេន និងផ្ដល់ជូន :**

| | | | |
|---|---|---|---|
| ១-ព្រះតេជគុណ | **ហ៊ិន ហន** | ព្រះចៅអធិការវត្តកគោរណ៍ | បច្ច័យចំនួន ៦២.៥០០ ដុល្លារ |
| ២-លោក | **អៀ សៅ** | សប្បុរសជនខ្មែររស់នៅសហរដ្ឋអាមេរិក | ថវិកាចំនួន ៣២.១៣០ ដុល្លារ |
| ៣-លោក | **ម៉ា រ៉ុង** | ប្រធានគណៈកម្មការសាងសង់ | ថវិកាចំនួន ៣០.១៦០ ដុល្លារ |
| ៤-ឧបាសិកា | **អៀ ឡាន្ត** | ឧបដ្ឋាកព្រះសង្ឃ | ថវិកាចំនួន ២៨.៤៧០ ដុល្លារ |
| ៥-លោក | **អ៊ុម សារឿន** | លេខាសមុហ៍អនុគណស្រុកថ្មគោល | ថវិកាចំនួន ២៦.៦៦០ ដុល្លារ |
| ៦-លោក | **ជី សាលឿត** | លេខាធិការកត់ត្រាវត្តកគោរណ៍ | ថវិកាចំនួន ២៦.១៥៧ ដុល្លារ |
| ៧-លោក | **សយ អេត** | គណៈកម្មការសាងសង់វត្តកគោរណ៍ | ថវិកាចំនួន ២៦.០៦០ ដុល្លារ |
| ៨-ឧបាសិកា | **ពៅ អឿន** | ឧបដ្ឋាកព្រះសង្ឃ | ថវិកាចំនួន ២៥.២៦០ ដុល្លារ |
| ៩-លោក | **មេ រ៉ាន់** | ប្រធានគណៈកម្មការអាចារ្យវត្តកគោរណ៍ | ថវិកាចំនួន ២៤.៨៦០ ដុល្លារ |

| | | | |
|---|---|---|---|
| ១០-លោក | **ពៅ វ៉ែន** | សប្បុរសជនខ្មែររស់នៅសហរដ្ឋអាមេរិក | ថវិកាចំនួន ២១.៥៨៣ ដុល្លារ |
| ១១-លោក | **ម្ជូន លួម** | សប្បុរសជននៅខេត្តបាត់ដំបង | ថវិកាចំនួន ២០.១០០ ដុល្លារ |
| ១២-លោក | **ប៊ុល ជុំ** | សប្បុរសជនខ្មែររស់នៅសហរដ្ឋអាមេរិក | ថវិកាចំនួន ១៨.៣៦៥ ដុល្លារ |
| ១៣-ឯកឧត្តម | **ឆាយ សារ៉េត** | សមាជិកក្រុមប្រឹក្សាខេត្តពោធិ៍សាត់ | ថវិកាចំនួន ១៥.៧០០ ដុល្លារ |
| ១៤-លោក | **កែវ នេង** | សប្បុរសជនខ្មែររស់នៅសហរដ្ឋអាមេរិក | ថវិកាចំនួន ១៣.៣០០ ដុល្លារ |
| ១៥-លោក | **ឈឿង សុខុម** | សប្បុរសជននៅខេត្តបាត់ដំបង | ថវិកាចំនួន ១២.៣៧៥ ដុល្លារ |
| ១៦-លោក | **ស៊ី ដាសាក់** | សប្បុរសជនខ្មែររស់នៅសហរដ្ឋអាមេរិក | ថវិកាចំនួន ១២.០៥៥ ដុល្លារ |
| ១៧-លោកស្រី | **ចាន់ សៀននេង** | សប្បុរសជននៅខេត្តបាត់ដំបង | ថវិកាចំនួន ១០.៦៥០ ដុល្លារ |

**ខ‿ មេដាយប្រាក់ស្ថាបនាជាតិចំនួន ០៥ គ្រឿង ផ្តល់ជូន :**

| | | | |
|---|---|---|---|
| ១-លោក | **យ៉ាត ឈឿង** | អនុប្រធានគណៈកម្មការវត្តកគោរណ៍ | ថវិកាចំនួន ៥.៣២០ ដុល្លារ |
| ២-លោក | **ចាន់ ឈិន** | អាចារ្យព្រិទ្ធាចារ្យ | ថវិកាចំនួន ៥.២៥០ ដុល្លារ |
| ៣-លោក | **មល់ មុត** | អនុប្រធានអាចារ្យវត្តកគោរណ៍ | ថវិកាចំនួន ៥.២០០ ដុល្លារ |
| ៤-លោក | **យ៉ាង អ៊ាត** | អាចារ្យព្រិទ្ធាចារ្យ | ថវិកាចំនួន ៥.១២០ ដុល្លារ |
| ៥-លោក | **សួស សារ៉េ** | សប្បុរសជនខ្មែររស់នៅសហរដ្ឋអាមេរិក | ថវិកាចំនួន ៥.១០០ ដុល្លារ |

**គ‿ មេដាយសំរិទ្ធស្ថាបនាជាតិចំនួន ០៨ គ្រឿង ផ្តល់ជូន :**

| | | | |
|---|---|---|---|
| ១-លោក | **និល ឈួន** | សមាជិកអាចារ្យវត្តកគោរណ៍ | ថវិកាចំនួន ៣.២១០ ដុល្លារ |
| ២-លោក | **ខូវ ធ្វី** | តំណាងពុទ្ធបរិស័ទ | ថវិកាចំនួន ៣.១៤០ ដុល្លារ |
| ៣-លោក | **ម៉ុន សាឃឿត** | អនុប្រធានអាចារ្យវត្តកគោរណ៍ | ថវិកាចំនួន ៣.១១០ ដុល្លារ |
| ៤-លោក | **រាំង ច្រាន្ត** | សមាជិកអាចារ្យវត្តកគោរណ៍ | ថវិកាចំនួន ៣.១០០ ដុល្លារ |
| ៥-លោក | **ឌី នាគ** | សមាជិកអាចារ្យវត្តកគោរណ៍ | ថវិកាចំនួន ៣.១០០ ដុល្លារ |
| ៦-លោក | **ម៉ូ ធូក** | សមាជិកអាចារ្យវត្តកគោរណ៍ | ថវិកាចំនួន ៣.១០០ ដុល្លារ |
| ៧-លោក | **ឡុង ហ៊ិន** | តំណាងពុទ្ធបរិស័ទ | ថវិកាចំនួន ៣.០១០ ដុល្លារ |
| ៨-ឧបាសិកា | **ង៉ែ ស្រ៊ន់** | តំណាងពុទ្ធបរិស័ទ | ថវិកាចំនួន ៣.០០៥ ដុល្លារ |

**មាត្រា ២.—**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អភិបាលខេត្តបាត់ដំបង និង សាមីខ្លួន ដែលមានឈ្មោះក្នុងមាត្រា១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០១០

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា២

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ២៥៥ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១ .-**

ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ប្រគេន និងផ្តល់ជូនសប្បុរសជននៅក្នុង និងក្រៅប្រទេសចំនួន ២១រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួនជួយកសាងសមិទ្ធផលនានាក្នុងវិស័យព្រះពុទ្ធសាសនា និង ហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ នៅ***វត្តទិបវ័ន្តកោះប៉ិនលី វត្តព្រៃជា*** និង***វត្តបន្ទាយត្រាវ*** ស្ថិតនៅក្នុងឃុំពត់សរ និងឃុំកណ្តឹង ស្រុកបាទី ខេត្តតាកែវ ដែលមានរាយព្រះនាម និងនាមដូចខាងក្រោម :

| | | |
|---|---|---|
| ១-ព្រះតេជគុណ **គង់ ចាន់ធឿន** | គង់នៅវត្តព្រៃជា | បច្ច័យចំនួន ២៨.០៥៥ ដុល្លារ |
| ២-ព្រះតេជគុណ **អៀវ សុវណ្ណ** | គង់នៅរាជធានីភ្នំពេញ | បច្ច័យចំនួន ១៣.៥០០ ដុល្លារ |
| ៣-ព្រះតេជគុណ **ឈាង សុវុឌ្ឍី** | គង់នៅវត្តទិបវ័ន្តកោះប៉ិនលី | បច្ច័យចំនួន ១៣.០០០ ដុល្លារ |
| ៤-ព្រះតេជគុណ **គង ព្រហ្ម** | គង់នៅវត្តអង្គចំណោមមានជ័យ | បច្ច័យចំនួន ១២.៧០០ ដុល្លារ |
| ៥-ព្រះតេជគុណ **គ្រឿន យឹន** | គង់នៅវត្តអង្គចំណោមមានជ័យ | បច្ច័យចំនួន ១២.០៥០ ដុល្លារ |
| ៦-ព្រះតេជគុណ **អ៊ី ម៉ូ** | គង់នៅវត្តព្រៃជា | បច្ច័យចំនួន ១០.៥០០ ដុល្លារ |
| ៧-លោកស្រី **នុយ ឈឿង** | សប្បុរសជនខ្មែររស់នៅសហរដ្ឋអាមេរិក | ថវិកាចំនួន ៤៥.០០០ ដុល្លារ |

| | | | |
|---|---|---|---|
| ៨-ឯកឧត្តម | **សែស វឌ្ឍសិត្ថា** | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកាចំនួន ១៦.៥០០ ដុល្លារ |
| ៩-លោកស្រី | **អោម ស៊ីន** | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកាចំនួន ១៥.០០០ ដុល្លារ |
| ១០-លោកជំទាវ | **ម៉ៅ សុន ឡៅ សារឿន** | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកាចំនួន ១៣.២០០ ដុល្លារ |
| ១១-លោក | **សុខ សុវណ្ណ** | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកាចំនួន ១២.៩០០ ដុល្លារ |
| ១២-លោក | **តាំង ទ្រី** | សប្បុរសជននៅខេត្តកណ្តាល | ថវិកាចំនួន ១២.២០០ ដុល្លារ |
| ១៣-លោក | **អ៊ិន សារិន** | សប្បុរសជននៅខេត្តកំពង់ស្ពឺ | ថវិកាចំនួន ១១.៨០០ ដុល្លារ |
| ១៤-លោក | **ឈាត ឆាយហុង** | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកាចំនួន ១១.៥២៥ ដុល្លារ |
| ១៥-លោកស្រី | **ជឹន សុខលី** | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកាចំនួន ១១.១៥០ ដុល្លារ |
| ១៦-លោកស្រី | **ហេង វន** | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកាចំនួន ១០.៨០០ ដុល្លារ |
| ១៧-លោក | **ត្រី ស្រ៊ីង** | សប្បុរសជននៅខេត្តតាកែវ | ថវិកាចំនួន ១០.៦០០ ដុល្លារ |
| ១៨-លោកស្រី | **ស៊ិន សៀង** | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកាចំនួន ១០.៥០០ ដុល្លារ |
| ១៩-លោក | **សៀម អៀងគុង** | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកាចំនួន ១០.៤០០ ដុល្លារ |
| ២០-លោក | **ស៊ូ សុខ** | សប្បុរសជននៅខេត្តកំពង់ស្ពឺ | ថវិកាចំនួន ១០.៣២០ ដុល្លារ |
| ២១-លោក | **ហ៊ួន ត្រី** | សប្បុរសជនខ្មែររស់នៅប្រទេសអូស្ត្រាលី | ថវិកាចំនួន ១០.៣០០ ដុល្លារ |

**មាត្រា ២ .—**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អភិបាលខេត្តតាកែវ និង សាមីខ្លួន ដែលមានឈ្មោះក្នុងមាត្រា១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ២០១០

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ..១៧...សសរ..

# សេចក្តីសម្រេច

## ស្តីពី

## ការបង្កើតគណៈកម្មការអន្តរក្រសួងរៀបចំការបោះជំរំយុវជនរដូវក្តៅ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ២១ អនក្រ/បក ចុះថ្ងៃទី ២៣ ខែមីនា ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

## ស ម្រេ ច

**ប្រការ ១ :**

ត្រូវបង្កើតគណៈកម្មការអន្តរក្រសួងមួយ សម្រាប់រៀបចំការបោះជំរំយុវជនរដូវក្តៅ ដោយបើកទូលាយឱ្យយុវជនចូលរួមពីគ្រប់មជ្ឈដ្ឋាន រួមទាំងយុវជនដែលមានដើមកំណើតខ្មែររស់នៅបរទេសបានចូលរួម ដែលមានសមាសភាពដូចខាងក្រោម ÷

១-ឯកឧត្តម **អ៊ឹម សិទ្ធី** រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ប្រធាន

| | | | |
|---|---|---|---|
| ២-ឯកឧត្តម | **ពុង យាទសែ** | ទីប្រឹក្សាផ្ទាល់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា | អនុប្រធាន |
| ៣-ឯកឧត្តម | **ជ័យ ចាប** | រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា | អនុប្រធាន |
| ៤-ឯកឧត្តម | **ស៊ាន មូរ៉ាត** | ទីប្រឹក្សាផ្ទាល់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងជាអនុរដ្ឋលេខាធិការ ក្រសួងអប់រំ យុវជន និងកីឡា | អនុប្រធានប្រចាំការ |
| ៥-ឯកឧត្តម | **អ៊ិន ថេរ** | អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាលហិរញ្ញវត្ថុ ក្រសួងអប់រំ យុវជន និងកីឡា | សមាជិក |
| ៦-ឯកឧត្តម | **ផន សូគីម** | អគ្គនាយកនៃអគ្គនាយកដ្ឋានយុវជនក្រសួងអប់រំ យុវជន និងកីឡា | សមាជិករាយការណ៍ |
| ៧-ឯកឧត្តម | **និត ថាវរិទ្ធ** | អគ្គនាយករងទូរទស្សន៍បាយ័ន | សមាជិក |
| ៨-ឯកឧត្តម | **មុខ សុទត្តិ** | សាកលវិទ្យាធិការនៃសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | សមាជិក |
| ៩-ឯកឧត្តម | **ញឹម ខេមរា** | អគ្គលេខាធិការរង នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ១០-ឯកឧត្តម | **ឡៅ ឈើទរ៉ាទ** | សាកលវិទ្យាធិការនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ក្រសួងអប់រំ យុវជន និងកីឡា | សមាជិក |
| ១១- ឯកឧត្តម | **យក់ ង៉ុយ** | សាកលវិទ្យាធិការនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ក្រសួងអប់រំ យុវជន និងកីឡា | សមាជិក |
| ១២- ឯកឧត្តម | **តូច ជឿន** | សាកលវិទ្យាធិការនៃសាកលវិទ្យាល័យមានជ័យ ក្រសួងអប់រំ យុវជន និងកីឡា | សមាជិក |
| ១៣-ឯកឧត្តម | **ម៉ៅ ធុន្នី** | អភិបាលរងខេត្តសៀមរាប | សមាជិក |
| ១៤-ឯកឧត្តម | **អ៊ុម រម្យណី** | នាយកវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជាក្រសួងអប់រំ យុវជននិងកីឡា | សមាជិក |
| ១៥-លោក | **ថ្លុខ ធឿន** | អគ្គនាយករងទេសចរណ៍ នៃក្រសួងទេសចរណ៍ | សមាជិក |
| ១៦-លោក | **ខៀវ រិទ្ធិយ៉ា** | អនុប្រធាននាយកដ្ឋានបុគ្គលិក នៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | សមាជិក |
| ១៧-លោក | **នួន សុមេធ** | នាយខុទ្ទកាល័យសាលារាជធានីភ្នំពេញ | សមាជិក |
| ១៨-លោក | **វ័ន្ន គំនិត** | ទីប្រឹក្សាច្បាប់ និងជាប្រធានសេវាកម្មគាំទ្រធនាគារកាណាឌីយ៉ា | សមាជិក |

**ប្រការ ២ :**

គណៈកម្មការនេះមានភារកិច្ចរៀបចំដំណើរការបោះជំរំយុវជនរដូវក្តៅ ដែលនឹងប្រព្រឹត្តទៅក្នុងខែកក្កដា

និងខែសីហា ឆ្នាំ២០១០ ឱ្យមានប្រសិទ្ធភាពខ្ពស់។

**ប្រការ ៣ :**

គណៈកម្មការនេះ ត្រូវបង្កើតលេខាធិការដ្ឋានអចិន្ត្រៃយ៍មួយ ដែលមានទីតាំងនៅក្រសួងអប់រំ យុវជន និងកីឡា ដើម្បីចាត់ចែងការងារប្រចាំថ្ងៃ និងត្រូវបង្កើតអនុគណៈកម្មការជំនាញមួយចំនួនតាមការចាំបាច់។

**ប្រការ ៤ :**

គណៈកម្មការនេះ មានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងអប់រំ យុវជន និងកីឡាសម្រាប់សម្រួលការងារ។

**ប្រការ ៥ :**

សមាជិកនៃគណៈកម្មការ និងអនុគណៈកម្មការនានា ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន។

**ប្រការ ៦ :**

ថវិកាចំណាយសម្រាប់ដំណើរការបោះជំរំយុវជនរដូវក្តៅ បានមកពីចំណូលរបស់សប្បុរសជន និងការរួមចំណែកថវិកាបដិភាគរបស់រដ្ឋ។

**ប្រការ ៧ :**

រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងទេសចរណ៍ អភិបាលនៃគណៈអភិបាលរាជធានីភ្នំពេញ អភិបាលនៃគណៈអភិបាលខេត្តសៀមរាប និងសាមីខ្លួនដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តសេចក្តីសម្រេចនេះ ឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែមីនា ឆ្នាំ ២០១០

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

***កន្លែងទទួល :***

*-ក្រសួងព្រះបរមរាជវាំង*
*-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
*-អគ្គលេខាធិការដ្ឋានរដ្ឋសភា*
*-អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល*
*-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
*-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
*-ធនាគារកាណាឌីយ៉ា*
*-ដូចប្រការ ៧*
*-រាជកិច្ច*
*-ឯកសារ-កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ០០៣ សហវ.អពដ

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០១០

# សេចក្តីជូនដំណឹង

## ស្តីពីការដាក់លិខិតប្រកាសពន្ធលើប្រាក់ចំណេញសម្រាប់ឆ្នាំជាប់ពន្ធ ២០០៩

អនុលោមតាមមាត្រា ៥ និងមាត្រា ២៩ នៃច្បាប់ស្តីពីសារពើពន្ធដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានកិត្តិយសសូមជម្រាបជូនដំណឹងដល់ លោក-លោកស្រី ជាអភិបាល បណ្ណាធិការ ឬកម្មសិទ្ធិករ របស់សហគ្រាសជាអ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស (របបពិត) ទាំងអស់ សូមជ្រាបអំពីកាតព្វកិច្ចដាក់លិខិតប្រកាសនិងបង់ពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ ២០០៩ ដូចខាងក្រោម :

១. សហគ្រាសដែលប្រើប្រាស់ឆ្នាំជាប់ពន្ធតាមឆ្នាំប្រតិទិន (០១ ខែមករា ដល់ ៣១ ខែធ្នូ) ត្រូវដាក់លិខិតប្រកាស និងបង់ពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ សម្រាប់ការិយបរិច្ឆេទឆ្នាំ២០០៩ យ៉ាងយឺតបំផុតត្រឹមថ្ងៃទី៣១ ខែមីនា ឆ្នាំ ២០១០ នៅរដ្ឋបាលសារពើពន្ធ ដែលមានសមត្ថកិច្ចគ្រប់គ្រងប្រមូលពន្ធលើសហគ្រាស ។

២. សហគ្រាសដែលត្រូវបានអនុញ្ញាតឱ្យប្រើប្រាស់ឆ្នាំជាប់ពន្ធខុសពីឆ្នាំប្រតិទិន ត្រូវដាក់លិខិតប្រកាសនិងបង់ពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំយ៉ាងយឺតបំផុតក្នុងរយៈវេលា ៣ខែ ក្រោយពីដំណាច់ឆ្នាំជាប់ពន្ធ ។

៣. សហគ្រាសដែលមានសាខាច្រើន ត្រូវដាក់លិខិតប្រកាសពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ ដែលបានមកពីលទ្ធផលសរុបរួមបញ្ចូលគ្នារបស់គ្រឹះស្ថានជាគោលដើមនិងគ្រប់សាខាទាំងអស់ ដោយភ្ជាប់មកជាមួយនូវរបាយការណ៍លទ្ធផលរបស់សាខានីមួយៗ ។ ដោយឡែកសម្រាប់សាខានីមួយៗ ត្រូវប្រកាសលទ្ធផលចំណេញ-ខាតរបស់សាខាតាមគំរូលិខិតប្រកាសពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ ជូនរដ្ឋបាលសារពើពន្ធនៅទីកន្លែងដែលសាខាជាប់ទាក់ទិននីមួយៗតាំងនៅ ។

៤. សហគ្រាសនីតិបុគ្គលដែលអនុវត្តគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ច្រើន ត្រូវដាក់លិខិតប្រកាស និងបង់ពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ តាមការណែនាំដោយឡែករបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

៥. ចំពោះតំណាងអ្នកជាប់ពន្ធ ទទួលបន្ទុកធ្វើទំនាក់ទំនងជាមួយរដ្ឋបាលសារពើពន្ធ ដាក់លិខិតប្រកាសពន្ធប្រចាំខែ ប្រចាំឆ្នាំ ត្រូវមានលិខិតប្រគល់សិទ្ធិជាលាយលក្ខណ៍អក្សរពីអ្នកជាប់ពន្ធ ដូចមានចែងក្នុងមាត្រា ១០៦ នៃច្បាប់ស្តីពីសារពើពន្ធ ។

កន្លងមក ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ពិនិត្យឃើញថា សហគ្រាសមួយចំនួនបានបំពេញលិខិតប្រកាសពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំមិនបានត្រឹមត្រូវគ្រប់ខ្ទង់នីមួយៗឡើយ ។ ដើម្បីបង្កភាពងាយស្រួលក្នុងការបំពេញលិខិតប្រកាសឱ្យបានត្រឹមត្រូវ អគ្គនាយកដ្ឋានពន្ធដារ បានរៀបចំសៀវភៅណែនាំសម្រាប់បំពេញលិខិតប្រកាស ។ ក្នុងករណី លោក-លោកស្រី មានចំងល់ផ្សេងៗ សូមទាក់ទងជាមួយការិយាល័យសេវាអ្នកជាប់ពន្ធ នៃនាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ សាខាពន្ធដារខណ្ឌ និងសាខាពន្ធដារខេត្ត-ក្រុង ដែលទាក់ទិន ។

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សង្ឃឹមនិងជឿជាក់ថា លោក-លោកស្រីជាអភិបាល បណ្ណាធិការ ឬកម្មសិទ្ធិកររបស់សហគ្រាស ពិតជាយកចិត្តទុកដាក់ អនុវត្តតាមសេចក្តីជូនដំណឹងនេះបានល្អប្រសើរ ។

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

គាត ឈន់

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
www.mef.gov.kh
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798
mef_adm@yahoo.com

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មការមូលបត្រកម្ពុជា

លេខ: ០១៤ គ.ម.ក.ប្រ.ក

លិខិតចូល

ថ្ងៃទី ០៣ ខែ ០៣ ឆ្នាំ2010

# ប្រកាស

## ស្តីពី

## ការរៀបចំ និងការប្រព្រឹត្តទៅនៃនាយកដ្ឋានស្រាវជ្រាវ បណ្តុះបណ្តាល អភិវឌ្ឍន៍ទីផ្សារមូលបត្រ និងទំនាក់ទំនងអន្តរជាតិ

*****

## ឧបនាយករដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
## និងជាប្រធានគណៈកម្មការមូលបត្រកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០១ ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីមូលបត្ររដ្ឋ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០០៧/០២៨ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន
- បានឃើញអនុក្រឹត្យលេខ ៩៧ អនក្រ/បក ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការមូលបត្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ/បក ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០៩ ស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន
- យោងតាមការអនុម័តនៃសម័យប្រជុំពេញអង្គរបស់គណៈកម្មការមូលបត្រកម្ពុជា នាថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០០៩

# ស ម្រេ ច

**ប្រការ ១.-**

ប្រកាសនេះមានគោលដៅកំណត់ពីការរៀបចំ និងការប្រព្រឹត្តទៅរបស់នាយកដ្ឋានស្រាវជ្រាវ បណ្តុះបណ្តាល អភិវឌ្ឍន៍ទីផ្សារមូលបត្រ និងទំនាក់ទំនងអន្តរជាតិ នៃគណៈកម្មការមូលបត្រកម្ពុជា ដែលមានតួនាទី និងភារកិច្ច ដូចមានចែងក្នុងអនុក្រឹត្យលេខ ៩៧ អនក្រ/បក ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការមូលបត្រកម្ពុជា (**គ.ម.ក.**)។

**ប្រការ ២.-**

នាយកដ្ឋានស្រាវជ្រាវ បណ្តុះបណ្តាល អភិវឌ្ឍន៍ទីផ្សារមូលបត្រ និងទំនាក់ទំនងអន្តរជាតិ ដឹកនាំដោយប្រធាន ០១ (មួយ) រូប និងមានអនុប្រធានមួយចំនួនជាជំនួយការ តាមការចាំបាច់។

**ប្រការ ៣.-**

នាយកដ្ឋានស្រាវជ្រាវ បណ្តុះបណ្តាល អភិវឌ្ឍន៍ទីផ្សារមូលបត្រ និងទំនាក់ទំនងអន្តរជាតិ មានការិយាល័យចំណុះចំនួន ០៣ (បី) ដូចខាងក្រោម ÷

១- ការិយាល័យស្រាវជ្រាវ និងអភិវឌ្ឍន៍ទីផ្សារមូលបត្រ

២- ការិយាល័យបណ្តុះបណ្តាល និងផ្សព្វផ្សាយ

៣- ការិយាល័យទំនាក់ទំនងអន្តរជាតិ

ការិយាល័យនីមួយៗត្រូវដឹកនាំដោយប្រធាន ០១ (មួយ) រូប និងមានអនុប្រធានមួយចំនួនជាជំនួយការ តាមការចាំបាច់។

អង្គការលេខរបស់នាយកដ្ឋានស្រាវជ្រាវ បណ្តុះបណ្តាល អភិវឌ្ឍន៍ទីផ្សារមូលបត្រ និងទំនាក់ទំនងអន្តរជាតិ ជាឧបសម្ព័ន្ធនៃប្រកាសនេះ។

**ប្រការ ៤.-**

ការិយាល័យស្រាវជ្រាវ និងអភិវឌ្ឍន៍ទីផ្សារមូលបត្រ មានតួនាទី និងភារកិច្ច ដូចខាងក្រោម ÷

- សិក្សាស្រាវជ្រាវអំពីយុទ្ធសាស្ត្រនានា និងរៀបចំគម្រោងផែនការមេដើម្បីអភិវឌ្ឍវិស័យមូលបត្រនៅព្រះរាជាណាចក្រកម្ពុជា
- រៀបចំយុទ្ធសាស្ត្រដើម្បីទាក់ទាញវិនិយោគិន អន្តរការីមូលបត្រ ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រ និងអ្នកចូលរួមក្នុងទីផ្សារមូលបត្រ
- សិក្សាវាយតម្លៃ និងផ្តល់យោបល់លើការបង្កើតឧបករណ៍ហិរញ្ញវត្ថុថ្មី មុននឹងផ្តល់ការអនុញ្ញាតឱ្យបោះផ្សាយលក់ជាសាធារណៈនៅលើទីផ្សារមូលបត្រ
- សិក្សាស្រាវជ្រាវ វិភាគ និងលើកជាយោបល់នូវរាល់ផលប៉ះពាល់ និងផលប្រយោជន៍ចំពោះក្រុមហ៊ុនដែលស្នើសុំការបោះផ្សាយលក់មូលបត្រជាសាធារណៈ
- សិក្សាប្រៀបធៀប និងវិភាគពីលក្ខខណ្ឌតម្រូវនៃការបោះផ្សាយលក់មូលបត្រ និងស្ថានភាពជាក់ស្តែងរបស់ក្រុមហ៊ុនដែលមានបំណងបោះផ្សាយលក់មូលបត្រជាសាធារណៈ
- សិក្សាស្រាវជ្រាវរៀបចំបង្កើតវិទ្យាស្ថានស្រាវជ្រាវ និងបណ្តុះបណ្តាលមូលបត្រកម្ពុជា
- សិក្សាស្រាវជ្រាវអំពីស្ថានភាពទីផ្សារ និងធ្វើការវិភាគអំពីសន្ទនីយភាព រួមទាំងតម្រូវការ និងការផ្គត់ផ្គង់មូលបត្រ ដោយលើកឡើងនូវយុទ្ធសាស្ត្រ ដើម្បីអភិវឌ្ឍទីផ្សារមូលបត្រ
- សិក្សាស្រាវជ្រាវ វិភាគ អំពីរាល់ផលប៉ះពាល់ដល់វិស័យមូលបត្រកម្ពុជា ដែលបណ្តាលមកពីកត្តាខាងក្នុង និងខាងក្រៅ
- សិក្សាស្រាវជ្រាវអំពីលទ្ធភាពនៃការបណ្តុះបណ្តាល និងការអប់រំវិស័យមូលបត្រនៅក្នុងកម្មវិធីសិក្សា
- សិក្សាស្រាវជ្រាវ និងរៀបចំគោលនយោបាយសម្រាប់ធ្វើសមាហរណកម្ម ក្នុងតំបន់ចំពោះទីផ្សារមូលបត្រ រួមទាំងការចុះបញ្ជីឆ្លងដែន ការទូទាត់និងជាត់ទាត់ និងការរក្សាទុកមូលបត្រ និងការទទួលស្គាល់ទៅវិញទៅមកនៃអន្តរការីមូលបត្រ
- សិក្សាស្រាវជ្រាវពីការធ្វើសុខដុមនីយកម្មនៃក្របខណ្ឌច្បាប់ និងបទប្បញ្ញត្តិទៅក្នុងតំបន់
- សិក្សាស្រាវជ្រាវ និងអភិវឌ្ឍទីផ្សារនិស្សន្ទ ឬទីផ្សារដេរីវេទីវ
- សិក្សាស្រាវជ្រាវ និងសំយោគព័ត៌មានផ្សេងៗពាក់ព័ន្ធនឹងវិស័យមូលបត្រជូនថ្នាក់ដឹកនាំនៃ **គ.ម.ក.**

- រៀបចំរចនានុក្រមសម្រាប់វិស័យមូលបត្រ
- រៀបចំរបាយការណ៍ជាប្រចាំពាក់ព័ន្ធនឹងការអនុវត្តការងាររបស់ការិយាល័យ
- អនុវត្តការងារផ្សេងទៀតតាមការប្រគល់ជូនរបស់ប្រធាននាយកដ្ឋាន។

**ប្រការ ៥.-**

ការិយាល័យបណ្តុះបណ្តាល និងផ្សព្វផ្សាយ មានតួនាទី និងភារកិច្ច ដូចខាងក្រោម ÷

- រៀបចំបទប្បញ្ញត្តិសម្រាប់ការគ្រប់គ្រងលើការបណ្តុះបណ្តាល ការអប់រំ និងការផ្សព្វផ្សាយពាក់ព័ន្ធនឹងវិស័យមូលបត្រ ដល់វិនិយោគិនសាធារណៈ អន្តរការីមូលបត្រ ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រ ប្រតិបត្តិករ និងអ្នកចូលរួមដទៃទៀតក្នុងទីផ្សារមូលបត្រ
- រៀបចំកម្មវិធីសម្រាប់ការបណ្តុះបណ្តាល ការអប់រំ និងការផ្សព្វផ្សាយដល់វិនិយោគិនសាធារណៈ អន្តរការីមូលបត្រ ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រ ប្រតិបត្តិករ និងអ្នកចូលរួមដទៃទៀតក្នុងទីផ្សារមូលបត្រ
- រៀបចំកម្មវិធីធ្វើតេស្ត និងការប្រលង ដើម្បីបញ្ជាក់ពីគុណវុឌ្ឍិរបស់បុគ្គលដែលតម្រូវដោយបទប្បញ្ញត្តិជាធរមាន
- ចូលរួមក្នុងការប្រលងជ្រើសរើសមន្ត្រីសម្រាប់បំពេញការងារក្នុង **គ.ម.ក.**
- រៀបចំគម្រោង និងធ្វើការបណ្តុះបណ្តាលដើម្បីពង្រឹងសមត្ថភាពដល់មន្ត្រីនៃ **គ.ម.ក.**
- សហការរៀបចំចាត់ចែង វគ្គសិក្សា សិក្ខាសាលា និងសន្និសីទពាក់ព័ន្ធនឹងវិស័យមូលបត្រ
- រៀបចំផែនការប្រចាំឆ្នាំសម្រាប់ការបណ្តុះបណ្តាល និងការផ្សព្វផ្សាយពាក់ព័ន្ធនឹងវិស័យមូលបត្រដល់វិនិយោគិនសាធារណៈ អន្តរការីមូលបត្រ ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រជាសាធារណៈ ប្រតិបត្តិករ និងអ្នកចូលរួមដទៃទៀតក្នុងទីផ្សារមូលបត្រ
- បូកសរុបការងារបណ្តុះបណ្តាល និងផ្សព្វផ្សាយដែលបានអនុវត្ត ដោយធ្វើការវិភាគលើផែនការបណ្តុះបណ្តាល និងផ្សព្វផ្សាយ និងការងារតម្រូវជាក់ស្តែង

- រៀបចំរបាយការណ៍ជាប្រចាំពាក់ព័ន្ធនឹងការអនុវត្តការងាររបស់ការិយាល័យ
- អនុវត្តការងារផ្សេងទៀតតាមការប្រគល់ជូនដោយប្រធាននាយកដ្ឋាន។

**ប្រការ ៦.-**

ការិយាល័យទំនាក់ទំនងអន្តរជាតិ មានតួនាទី និងភារកិច្ច ដូចខាងក្រោម ៖

- រៀបចំផែនការបង្កើតកិច្ចសហប្រតិបត្តិការជាមួយសមភាគីនៃគណៈកម្មការមូលបត្រនៃប្រទេសដទៃ ដៃគូអភិវឌ្ឍន៍ សមាគម និងអង្គការអន្តរជាតិនានា
- ធ្វើទំនាក់ទំនងដើម្បីបង្កើតកិច្ចសហប្រតិបត្តិការ ជាមួយគណៈកម្មការមូលបត្រនៃបណ្តាប្រទេសក្នុងតំបន់ និងពិភពលោក
- រៀបចំចាត់ចែងទទួលបដិសណ្ឋារកិច្ចភ្ញៀវ ឬប្រតិភូអន្តរជាតិរបស់ **គ.ម.ក.**
- ចូលរួមរៀបចំវេទិកាអន្តរជាតិពាក់ព័ន្ធនឹងវិស័យមូលបត្រ
- សម្របសម្រួលកិច្ចជំនួបរវាងភ្ញៀវ ឬប្រតិភូអន្តរជាតិរបស់ **គ.ម.ក.** ជាមួយស្ថាប័នដៃគូអភិវឌ្ឍន៍ និងអង្គការពាក់ព័ន្ធនានា
- សម្របសម្រួល និងរៀបចំកម្មវិធីបេសកកម្មក្រៅប្រទេសនីមួយៗរបស់ថ្នាក់ដឹកនាំនៃ **គ.ម.ក.**
- សម្របសម្រួល និងប្រមូលផ្តុំព័ត៌មានក្នុងការអនុវត្តអនុស្សារណៈនៃការយោគយល់គ្នា និងកិច្ចព្រមព្រៀងផ្សេងទៀត
- ទំនាក់ទំនងរកជំនួយកិច្ចសហប្រតិបត្តិការ រួមទាំងហិរញ្ញប្បទានឥតសំណងពីសមភាគីនៃគណៈកម្មការមូលបត្រដៃគូអភិវឌ្ឍន៍ និងអង្គការអន្តរជាតិនានាក្នុងការអភិវឌ្ឍវិស័យមូលបត្រនៅក្នុងព្រះរាជាណាចក្រកម្ពុជា
- រៀបចំរបាយការណ៍ជាប្រចាំពាក់ព័ន្ធនឹងការអនុវត្តការងាររបស់ការិយាល័យ
- អនុវត្តការងារផ្សេងទៀតតាមការប្រគល់ជូនដោយប្រធាននាយកដ្ឋាន។

**ប្រការ ៧.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ៨.-**

អគ្គនាយក អគ្គនាយករងនៃគណៈកម្មការមូលបត្រកម្ពុជា ប្រធាននាយកដ្ឋានស្រាវ-ជ្រាវ បណ្ដុះបណ្ដាល អភិវឌ្ឍន៍ទីផ្សារមូលបត្រ និងទំនាក់ទំនងអន្តរជាតិ ប្រធាននាយកដ្ឋាន និងអង្គភាពពាក់ព័ន្ធចំណុះឱ្យគណៈកម្មការមូលបត្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តតាមប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ២០០៩

**គាត ឈន់**

**ចម្លងជូន :**

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្ដម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ធនាគារជាតិនៃកម្ពុជា
- ក្រសួងពាណិជ្ជកម្ម
- ក្រសួងយុត្តិធម៌
- សមាជិក **គ.ម.ក.**

"ដើម្បីជូនជ្រាប"

- ដូចប្រការ ៨

"ដើម្បីអនុវត្ត"

- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ឧបសម្ព័ន្ធ ប្រកាសលេខ ០១៤ គយក.ប្រ.ក
ចុះថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ ២០០៩
អង្គការលេខរបស់នាយកដ្ឋានស្រាវជ្រាវ បណ្តុះបណ្តាល អភិវឌ្ឍន៍ទីផ្សារមូលបត្រ
និងទំនាក់ទំនងអន្តរជាតិ នៃគណៈកម្មការមូលបត្រកម្ពុជា



ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មការមូលបត្រកម្ពុជា

លេខៈ........០១៥........គ ម ក .ប្រ.ក

លិខិតចូល

ថ្ងៃទី.០៣...ខែ.មីនា...ឆ្នាំ២០១០

# ប្រកាស

## ស្តីពី

## ការរៀបចំ និងការប្រព្រឹត្តទៅនៃនាយកដ្ឋានត្រួតពិនិត្យផ្សារមូលបត្រ នៃគណៈកម្មការមូលបត្រកម្ពុជា

*****

## ឧបនាយករដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
## និងជាប្រធានគណៈកម្មការមូលបត្រកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០១ ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីមូលបត្ររដ្ឋ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០០៧/០២៨ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន
- បានឃើញអនុក្រឹត្យលេខ ៩៧ អនក្រ/បក ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការមូលបត្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ/បក ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០៩ ស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន
- យោងតាមការអនុម័តនៃសម័យប្រជុំពេញអង្គរបស់គណៈកម្មការមូលបត្រកម្ពុជា នាថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៩

# ស ម្រេ ច

**ប្រការ ១.-**

ប្រកាសនេះមានគោលដៅកំណត់ពីការរៀបចំ និងការប្រព្រឹត្តទៅរបស់នាយកដ្ឋានត្រួតពិនិត្យទីផ្សារមូលបត្រ នៃគណៈកម្មការមូលបត្រកម្ពុជា ដែលមានតួនាទី និងភារកិច្ចដូចមានចែងក្នុងអនុក្រឹត្យលេខ ៩៧ អនក្រ/បក ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការមូលបត្រកម្ពុជា (**គ.ម.ក.**)។

**ប្រការ ២.-**

នាយកដ្ឋានត្រួតពិនិត្យទីផ្សារមូលបត្រដឹកនាំដោយប្រធាន ០១ (មួយ) រូប និងមានអនុប្រធានមួយចំនួនជាជំនួយការ តាមការចាំបាច់។

**ប្រការ ៣.-**

នាយកដ្ឋានត្រួតពិនិត្យទីផ្សារមូលបត្រមានការិយាល័យចំណុះចំនួន ០៣ (បី) ដូចខាងក្រោម ÷

១- ការិយាល័យត្រួតពិនិត្យប្រតិបត្តិការទីផ្សារមូលបត្រ

២- ការិយាល័យត្រួតពិនិត្យប្រព័ន្ធផាត់ទាត់ និងទូទាត់មូលបត្រ

៣- ការិយាល័យត្រួតពិនិត្យសេវារក្សាទុកមូលបត្រ

ការិយាល័យនីមួយៗត្រូវដឹកនាំដោយប្រធាន ០១ (មួយ) រូប និងមានអនុប្រធានមួយចំនួនជាជំនួយការ តាមការចាំបាច់។

អង្គការលេខរបស់នាយកដ្ឋានត្រួតពិនិត្យទីផ្សារមូលបត្រ ជាឧបសម្ព័ន្ធនៃប្រកាសនេះ។

**ប្រការ ៤.-**

ការិយាល័យត្រួតពិនិត្យប្រតិបត្តិការទីផ្សារមូលបត្រ មានតួនាទី និងភារកិច្ច ដូចខាងក្រោម ÷

- រៀបចំបទប្បញ្ញត្តិ ឬលក្ខខណ្ឌតម្រូវនានាសម្រាប់ផ្តល់ការអនុញ្ញាតឱ្យធ្វើជាប្រតិបត្តិករទីផ្សារមូលបត្រ

គណៈកម្មការមូលបត្រកម្ពុជា

- ពិនិត្យ និងផ្ដល់យោបល់លើពាក្យស្នើសុំការអនុញ្ញាតដើម្បីធ្វើជាប្រតិបត្តិករទីផ្សារមូលបត្រ
- ត្រួតពិនិត្យ និងតាមដានលើការផ្គត់ផ្គង់ប្រព័ន្ធជួញដូរមូលបត្រ និងប្រតិបត្តិការផ្សេងៗទៀតរបស់ប្រតិបត្តិករទីផ្សារមូលបត្រ
- ត្រួតពិនិត្យការអនុវត្តតាមលក្ខខណ្ឌតម្រូវនៃការអនុញ្ញាតរបស់ប្រតិបត្តិករទីផ្សារមូលបត្រ
- ត្រួតពិនិត្យការអនុវត្តវិធានប្រតិបត្តិការ និងសេចក្ដីណែនាំរបស់ប្រតិបត្តិករទីផ្សារមូលបត្រ
- ឃ្លាំមើល និងត្រួតពិនិត្យដំណើរការនៃការអនុវត្តបញ្ជាទិញ-លក់មូលបត្រប្រចាំថ្ងៃ របស់ប្រតិបត្តិករទីផ្សារមូលបត្រ
- ឃ្លាំមើល និងត្រួតពិនិត្យដំណើរការបន្ស៊ីថ្លៃមូលបត្រ (Price Matching) ប្រចាំថ្ងៃរបស់ប្រតិបត្តិករទីផ្សារមូលបត្រ
- តាមដាន និងឃ្លាំមើលប្រតិបត្តិការជួញដូរនៅក្នុងទីផ្សារមូលបត្រក្រៅប្រព័ន្ធ (Over-The-Counter-OTC)
- ពិនិត្យ និងផ្ដល់យោបល់លើការស្នើសុំបង្កើតសន្ទស្សន៍មូលបត្រ ក្នុងទីផ្សារមូលបត្រ
- គ្រប់គ្រង និងត្រួតពិនិត្យការផ្សព្វផ្សាយសន្ទស្សន៍មូលបត្រនានា ក្នុងទីផ្សារមូលបត្រ
- ឃ្លាំមើលសកម្មភាពជួញដូរមូលបត្រផ្សេងៗ ដែលអាចពាក់ព័ន្ធនឹងការប្រព្រឹត្តល្មើស ការជួញដូរផ្ទៃក្នុង និងការជួញដូរមិនប្រក្រតីក្នុងទីផ្សារមូលបត្រ
- រៀបចំករណីសង្ស័យប្រព្រឹត្តល្មើសផ្សេងៗ ដើម្បីបញ្ជូនទៅនាយកដ្ឋានកិច្ចការគតិយុត្ត
- ចូលរួមសិក្សា និងរៀបចំបទប្បញ្ញត្តិពាក់ព័ន្ធ ដើម្បីអភិវឌ្ឍទីផ្សារនិស្សន្ទ ឬទីផ្សារដេរីវេទីវ (Derivative Market)
- សិក្សា និងវិភាគគោលនយោបាយពាក់ព័ន្ធនឹងការធ្វើសមាហរណកម្មមូលបត្រក្នុងក្របខណ្ឌតំបន់ និងពិភពលោក
- សិក្សា វិភាគ និងធ្វើរបាយការណ៍អំពីការវាយតំលៃស្ថានភាពទីផ្សារមូលបត្ររួមទាំងសន្ទនីយភាព និងទំនោររបស់ទីផ្សារ
- ចងក្រងស្ថិតិ និងគ្រប់គ្រងទិន្នន័យនៃប្រតិបត្តិការជួញដូរមូលបត្រប្រចាំថ្ងៃ
- រៀបចំរបាយការណ៍ជាប្រចាំពាក់ព័ន្ធនឹងការអនុវត្តការងាររបស់ការិយាល័យ
- អនុវត្តការងារផ្សេងៗទៀតតាមការប្រគល់ជូនរបស់ប្រធាននាយកដ្ឋាន។

ប្រការ ៥.-

ការិយាល័យត្រួតពិនិត្យប្រព័ន្ធផាត់ទាត់ និងទូទាត់មូលបត្រ មានតួនាទី និងភារកិច្ចដូចខាងក្រោម ÷

- រៀបចំបទប្បញ្ញត្តិ ឬលក្ខខណ្ឌតម្រូវនានាសម្រាប់ផ្តល់ការអនុញ្ញាតឱ្យធ្វើជាប្រតិបត្តិករប្រព័ន្ធផាត់ទាត់ និងទូទាត់មូលបត្រ
- ពិនិត្យ និងផ្តល់យោបល់លើពាក្យស្នើសុំការអនុញ្ញាតដើម្បីធ្វើជាប្រតិបត្តិករប្រព័ន្ធផាត់ទាត់ និងទូទាត់មូលបត្រ
- រៀបចំបទប្បញ្ញត្តិ ឬលក្ខខណ្ឌតម្រូវនានាដើម្បីកំណត់គុណវុឌ្ឍិ អនុញ្ញាតអោយធ្វើជាភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ
- ពិនិត្យ និងផ្តល់យោបល់លើគុណវឌ្ឍិរបស់បុគ្គលស្នើសុំធ្វើជាភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ
- ឃ្លាំមើល និងត្រួតពិនិត្យការបញ្ជូន និងការទទួលព័ត៌មាន ដើម្បីធ្វើការផាត់ទាត់ និងដើម្បីធ្វើការទូទាត់
- រៀបចំគោលការណ៍ណែនាំ ដើម្បីពង្រឹងប្រតិបត្តិការរបស់ភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ
- ត្រួតពិនិត្យ និងឃ្លាំមើលដំណើរការផាត់ទាត់ និងទូទាត់មូលបត្រ
- ពិនិត្យរបាយការណ៍ប្រតិបត្តិការទូទាត់មូលបត្រ និងទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ
- សិក្សា និងវិភាគគោលនយោបាយពាក់ព័ន្ធនឹងការធ្វើសមាហរណកម្មប្រព័ន្ធផាត់-ទាត់និងទូទាត់មូលបត្រ ក្នុងក្របខណ្ឌតំបន់ និងពិភពលោក
- រៀបចំករណីសង្ស័យប្រព្រឹត្តល្មើសអំពីការផាត់ទាត់ និងទូទាត់ ដើម្បីបញ្ជូនទៅនាយកដ្ឋានកិច្ចការគតិយុត្ត
- សិក្សា វិភាគ និងធ្វើរបាយការណ៍អំពីការវាយតំលៃស្ថានភាពនៃប្រតិបត្តិការផាត់ទាត់ និងទូទាត់ក្នុងវិស័យមូលបត្រ
- ចងក្រងស្ថិតិ និងគ្រប់គ្រងទិន្នន័យនៃប្រតិបត្តិការផាត់ទាត់ និងទូទាត់ ប្រចាំថ្ងៃ
- គ្រប់គ្រងទ្រព្យសម្បត្តិ និងរៀបចំបញ្ជីសារពើភណ្ឌរបស់នាយកដ្ឋានដែល **គ.ម.ក.** ប្រគល់ឱ្យ
- រៀបចំរបាយការណ៍ជាប្រចាំពាក់ព័ន្ធនឹងការអនុវត្តការងាររបស់ការិយាល័យ
- អនុវត្តការងារផ្សេងៗទៀតតាមការប្រគល់ជូនរបស់ប្រធាននាយកដ្ឋាន។

**ប្រការ ៦.-**

ការិយាល័យត្រួតពិនិត្យសេវារក្សាទុកមូលបត្រ មានតួនាទី និងភារកិច្ច ដូចខាងក្រោម ៖

- រៀបចំបទប្បញ្ញត្តិ ឬលក្ខខណ្ឌតម្រូវនានា សម្រាប់ផ្តល់ការអនុញ្ញាតឱ្យធ្វើជាប្រតិបត្តិកររក្សាទុកមូលបត្រ
- ពិនិត្យ និងផ្តល់យោបល់លើពាក្យស្នើសុំការអនុញ្ញាតដើម្បីធ្វើជាប្រតិបត្តិកររក្សាទុកមូលបត្រ
- ឃ្លាំមើល និងត្រួតពិនិត្យដំណើរការដាក់ផ្ញើ ដក និងផ្ទេរមូលបត្រ
- ឃ្លាំមើល និងត្រួតពិនិត្យដំណើរការរក្សាទុកមូលបត្រ
- ឃ្លាំមើល និងត្រួតពិនិត្យការចេញវិញ្ញាបនបត្រជារូបវន្តទទួលស្គាល់មូលបត្រ
- ឃ្លាំមើល និងត្រួតពិនិត្យប្រតិបត្តិការនៃការគ្រប់គ្រងបញ្ជីភាគហ៊ុនិក និងបញ្ជីអ្នកកាន់កាប់មូលបត្រផ្សេងទៀត
- ឃ្លាំមើល និងត្រួតពិនិត្យដំណើរនៃការផ្តល់ការអនុវត្តសិទ្ធិភាគលាភ សិទ្ធិបោះឆ្នោត និងសិទ្ធិផ្សេងទៀតរបស់អ្នកកាន់កាប់មូលបត្រ
- សិក្សា និងវិភាគគោលនយោបាយពាក់ព័ន្ធនឹងការធ្វើសមាហរណកម្មសេវារក្សាទុកមូលបត្រ ក្នុងក្របខណ្ឌតំបន់ និងពិភពលោក
- រៀបចំករណីសង្ស័យប្រព្រឹត្តល្មើសពាក់ព័ន្ធនឹងការដាក់ផ្ញើ ការដក ការផ្ទេរ និងការរក្សាទុកមូលបត្រ ដើម្បីបញ្ជូនទៅនាយកដ្ឋានកិច្ចការគតិយុត្ត
- សិក្សា វិភាគ និងធ្វើរបាយការណ៍អំពីការវាយតំលៃស្ថានភាពរក្សាទុកមូលបត្រ ការគ្រប់គ្រងបញ្ជីអ្នកកាន់កាប់មូលបត្រ និងការអនុវត្តសិទ្ធិនានា
- ចងក្រងស្ថិតិ និងគ្រប់គ្រងទិន្នន័យនៃប្រតិបត្តិការដាក់ផ្ញើ ដក ផ្ទេរ និងរក្សាទុកមូលបត្រ
- រៀបចំរបាយការណ៍ជាប្រចាំពាក់ព័ន្ធនឹងការអនុវត្តការងាររបស់ការិយាល័យ
- អនុវត្តការងារផ្សេងៗទៀតតាមការប្រគល់ជូនរបស់ប្រធាននាយកដ្ឋាន។

**ប្រការ ៧.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ៨.-**

អគ្គនាយក អគ្គនាយករងនៃគណៈកម្មការមូលបត្រកម្ពុជា ប្រធាននាយកដ្ឋានត្រួត-ពិនិត្យទីផ្សារមូលបត្រ ប្រធាននាយកដ្ឋាន និងអង្គភាពពាក់ព័ន្ធចំណុះឱ្យគណៈកម្មការមូលបត្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តតាមប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី០១ ខែ ធ្នូ ឆ្នាំ២០០៩

**ភាគ ឈន់**

**ចម្លងជូន :**

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន**
  នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងយុត្តិធម៌
- ក្រសួងពាណិជ្ជកម្ម
- ធនាគារជាតិនៃកម្ពុជា
- គណៈកម្មការមូលបត្រកម្ពុជា និងសមាជិក **គ.ម.ក.**
  "ដើម្បីជូនជ្រាប"
- ដូចប្រការ ៨
  "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ឧបសម្ព័ន្ធ ប្រកាសលេខ ០១៥ ជគក.ប្រ.ក

**ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០០៩**

**អង្គការលេខរបស់នាយកដ្ឋានត្រួតពិនិត្យទីផ្សារមូលបត្រ**

**នៃគណៈកម្មការមូលបត្រកម្ពុជា**



**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**គណៈកម្មការមូលបត្រកម្ពុជា**

លេខៈ ០១៦ គ.ម.ក.ប្រ.ក

លិខិតចូល
ថ្ងៃទី០៣...ខែ៣...ឆ្នាំ2010

# ប្រកាស

# ស្ដីពី

# ការរៀបចំ និងការប្រព្រឹត្តទៅនៃអង្គភាពសវនកម្មផ្ទៃក្នុង នៃគណៈកម្មការមូលបត្រកម្ពុជា

*****

## ឧបនាយករដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
## និងជាប្រធានគណៈកម្មការមូលបត្រកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣០០/១១ ចុះថ្ងៃទី០៣ ខែមិនា ឆ្នាំ២០០០ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០១ ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីមូលបត្ររដ្ឋ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០០៧/០២៨ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន
- បានឃើញអនុក្រឹត្យលេខ ៤០ អនក្រ/បក ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៥ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃសវនកម្មផ្ទៃក្នុងនៅតាមបណ្ដាស្ថាប័ន ក្រសួង និងសហគ្រាសសាធារណៈ

- បានឃើញអនុក្រឹត្យលេខ ៩៧ អនក្រ/បក ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការមូលបត្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ/បក ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០៩ ស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន
- យោងតាមការអនុម័តនៃសម័យប្រជុំពេញអង្គរបស់គណៈកម្មការមូលបត្រកម្ពុជា នាថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៩

## ស ម្រេ ច

**ប្រការ ១.-**

ប្រកាសនេះមានគោលដៅកំណត់ពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អង្គភាពសវនកម្មផ្ទៃក្នុង នៃគណៈកម្មការមូលបត្រកម្ពុជា ដែលមានតួនាទី និងភារកិច្ច ដូចមានចែងក្នុងអនុក្រឹត្យលេខ ៩៧ អនក្រ/បក ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការមូលបត្រកម្ពុជា (**គ.ម.ក.**)។

**ប្រការ ២.-**

អង្គភាពសវនកម្មផ្ទៃក្នុង នៃគណៈកម្មការមូលបត្រកម្ពុជា ត្រូវទទួលខុសត្រូវអនុវត្តមុខងារឯករាជ្យស្របតាមស្តង់ដារ និងក្រមសីលធម៌វិជ្ជាជីវៈនៃសវនកម្មផ្ទៃក្នុង ដើម្បីពិនិត្យវិភាគ និងវាយតម្លៃលើសកម្មភាពនៃនាយកដ្ឋានរបស់ **គ.ម.ក.** ដោយផ្តល់នូវអនុសាសន៍ និងមតិយោបល់កែលំអ សំដៅជួយឱ្យគ្រប់បណ្តានាយកដ្ឋានទាំងនោះ បំពេញភារកិច្ចប្រកបដោយប្រសិទ្ធភាពខ្ពស់។ ដើម្បីសម្រេចគោលដៅនេះ មន្ត្រីរបស់អង្គភាពសវនកម្មផ្ទៃក្នុងត្រូវមានសិទ្ធិសេរីភាពពេញលេញក្នុងការត្រួតពិនិត្យលើគ្រប់សកម្មភាព គ្រប់ផ្នែក រាល់បញ្ជិកាកត់ត្រា ទ្រព្យសម្បត្តិ និងបុគ្គលិក។

**ប្រការ ៣.-**

អង្គភាពសវនកម្មផ្ទៃក្នុងត្រូវដឹកនាំដោយប្រធាន ០១ (មួយ) រូប និងមានអនុប្រធានមួយចំនួនជាជំនួយការ តាមការចាំបាច់។

**ប្រការ ៤.-**

អង្គភាពសវនកម្មផ្ទៃក្នុងមានការិយាល័យចំណុះចំនួន ០២ (ពីរ) ដូចខាងក្រោម ៖

១- ការិយាល័យសវនកម្មទី១ : ទទួលខុសត្រូវកិច្ចការរដ្ឋបាល និងធ្វើសវនកម្មលើនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ នាយកដ្ឋានកិច្ចការគតិយុត្ត និងនាយកដ្ឋានស្រាវជ្រាវ បណ្តុះបណ្តាល អភិវឌ្ឍន៍ទីផ្សារមូលបត្រ និងទំនាក់ទំនងអន្តរជាតិ។

២- ការិយាល័យសវនកម្មទី២ : ទទួលខុសត្រូវធ្វើសវនកម្មលើនាយកដ្ឋានត្រួតពិនិត្យអន្តរការីមូលបត្រ នាយកដ្ឋានគ្រប់គ្រងការបោះផ្សាយលក់មូលបត្រ និងនាយកដ្ឋានត្រួតពិនិត្យទីផ្សារមូលបត្រ។

ការិយាល័យនីមួយៗត្រូវដឹកនាំដោយប្រធាន ០១ (មួយ) រូប និងមានអនុប្រធានមួយចំនួនជាជំនួយការ តាមការចាំបាច់។

អង្គការលេខរបស់អង្គភាពសវនកម្មផ្ទៃក្នុង ជាឧបសម្ព័ន្ធនៃប្រកាសនេះ។

**ប្រការ ៥.-**

ការិយាល័យចំណុះអង្គភាពសវនកម្មផ្ទៃក្នុង មានតួនាទី និងភារកិច្ច ដូចខាងក្រោម÷

- ពិនិត្យឡើងវិញលើមុខងារ សកម្មភាព កម្មវិធី និងប្រតិបត្តិការនានារបស់ **គ.ម.ក.** ក្នុងការិយបរិច្ឆេទសមស្រប ដើម្បីកំណត់ការអនុវត្តឱ្យបានសមស្រប តាមការរៀបចំផែនការ ការចេញបទបញ្ជានិងបទប្បញ្ញត្តិផ្សេងៗ ការចាត់តាំងការងារ និងការត្រួតពិនិត្យ ដោយផ្អែកតាមគោលនយោបាយ ការណែនាំរបស់ថ្នាក់ដឹកនាំ និងនីតិវិធីនៃការគ្រប់គ្រងជាធរមាន និងស្របតាមគោលដៅរបស់ **គ.ម.ក.**
- កំណត់ភាពសមស្រប ភាពគ្រប់គ្រាន់ និងប្រសិទ្ធភាពនៃប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុង ផ្នែកគណនេយ្យ រដ្ឋបាល និងប្រតិបត្តិការរបស់ **គ.ម.ក.**
- ពិនិត្យឡើងវិញលើភាពដែលអាចជឿជាក់បាន ភាពច្បាស់លាស់ ភាពទាន់ពេលវេលា និងភាពពេញលេញនៃព័ត៌មានហិរញ្ញវត្ថុ និងប្រត្តិបត្តិការ ព្រមទាំងវិធីសាស្ត្រដែលប្រើប្រាស់ក្នុងការកំណត់អត្តសញ្ញាណ ការវាស់វែង ចំណាត់ថ្នាក់ និងការរៀបចំរបាយការណ៍អំពីព័ត៌មានទាំងនោះ
- ពិនិត្យឡើងវិញលើប្រព័ន្ធដែលបានបង្កើតរួច ដើម្បីធានាភាពត្រឹមត្រូវតាមគោលនយោបាយ ផែនការ នីតិវិធីច្បាប់ និងបទប្បញ្ញត្តិនានាដែលមានឥទ្ធិពលសំខាន់លើកិច្ចប្រតិបត្តិការ និងរបាយការណ៍ ហើយលើកសំណើកែលំអ ឬកែតម្រូវប្រសិនបើមានកំហុស

- ពិនិត្យឡើងវិញលើការគ្រប់គ្រង ថែទាំ ការពារ និងផ្ទៀងផ្ទាត់ទ្រព្យសម្បត្តិរបស់ **គ.ម.ក.**
- វាយតម្លៃភាពសន្សំសំចៃ និងប្រសិទ្ធភាពសេដ្ឋកិច្ចនៃការប្រើប្រាស់ធនធានរបស់ **គ.ម.ក.** ហើយលើកសំណើដោះស្រាយ និងកែលំអ
- ធ្វើសវនកម្មលើប្រតិបត្តិការចំណូល និងចំណាយ ដើម្បីបញ្ជាក់ពីភាពត្រឹមត្រូវនៃការអនុវត្តថវិការបស់ **គ.ម.ក.** រួមទាំងភាពត្រឹមត្រូវនៃរបាយការណ៍ហិរញ្ញវត្ថុ
- ធ្វើសវនកម្មលើការអនុវត្តកម្មវិធី និងគម្រោងចំណាយ ដោយធ្វើការប្រៀបធៀបលទ្ធផលជាមួយគោលដៅ និងគោលបំណងដែលបានដាក់ចេញ
- ចូលរួមបង្កើតផែនការ ការអភិវឌ្ឍ និងធ្វើសវនកម្មលើប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានដើម្បីឱ្យប្រព័ន្ធទាំងនោះឆ្លើយតបតាមគោលបំណង និងគោលដៅដែលបានគ្រោងទុក ហើយទទួលបានលទ្ធផលមានសុវត្ថិភាព និងប្រសិទ្ធភាពខ្ពស់
- ធ្វើសវនកម្មលើនីតិវិធី និងការអនុវត្តនីតិវិធី ដើម្បីធានាថា វិធានការដែលបានដាក់ចេញគឺក្នុងគោលបំណងការពារមិនឱ្យមានការកេងបន្លំ
- រៀបចំផែនការសវនកម្មប្រចាំឆ្នាំជូនថ្នាក់ដឹកនាំ **គ.ម.ក.** ពិនិត្យ និងសម្រេច
- ធ្វើសវនកម្មលើភាពសមស្របនៃការគ្រប់គ្រងធនធានមនុស្ស រចនាសម្ព័ន្ធ ចំនួនមន្ត្រី ជំនាញវិជ្ជាជីវៈ ឋានៈ តួនាទី និងការលើកទឹកចិត្ត
- ធ្វើសវនកម្មលើភាពត្រឹមត្រូវ ភាពទាន់ពេល ភាពពេញលេញ នៃប្រព័ន្ធត្រួតពិនិត្យ ប្រព័ន្ធកត់ត្រាព័ត៌មាន និងកិច្ចបញ្ជិកាគណនេយ្យ
- ធ្វើសវនកម្មលើការអនុវត្តបទបញ្ជាផ្ទៃក្នុងស្តីពីការគ្រប់គ្រងមន្ត្រីជំនាញគ្រប់ជាន់ថ្នាក់របស់ **គ.ម.ក.** និងលើការអនុវត្តលក្ខន្តិកៈនៃមន្ត្រីរបស់ **គ.ម.ក.**
- ធ្វើរបាយការណ៍សវនកម្មជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធាននៃ **គ.ម.ក.** អំពីការប្រព្រឹត្តទៅរបស់នាយកដ្ឋានដែលបានធ្វើសវនកម្មរួច
- ផ្តល់សេចក្តីសន្និដ្ឋាន និងអនុសាសន៍ជូនប្រធាននាយកដ្ឋានដែលទទួលការធ្វើសវនកម្មដើម្បីធ្វើការកែលំអ ហើយរបាយការណ៍សវនកម្មពេញលេញត្រូវផ្តល់ជូនថ្នាក់ដឹកនាំ **គ.ម.ក.** ពិនិត្យ និងផ្តល់ការណែនាំ
- រក្សារបាយការណ៍សវនកម្មឱ្យបានល្អសម្រាប់ជាមូលដ្ឋានតាមដាន ផ្ទៀងផ្ទាត់លើវឌ្ឍនភាពនៃការអនុវត្តអនុសាសន៍កែលំអ
- ប្រមូល និងតាមដានជាប្រចាំនូវឯកសារគតិយុត្ត និងសកម្មភាពកែទម្រង់ផ្សេងៗរបស់នាយកដ្ឋាននីមួយៗ

- សហការជាមួយនាយកដ្ឋាននានាសំដៅកសាងមូលដ្ឋានព័ត៌មានឱ្យបានគ្រប់ជ្រុងជ្រោយ ដើម្បីវាយតម្លៃឱ្យបានសុក្រឹត
